# ២២.ព្រេងទាក់ទងនឹងទង់នាគ - ទង់រលក - ទង់ក្រពើ

---

ទង់នាគ- ទង់រលក និង ទង់ក្រពើនេះ មិនមែនទើបតែនឹងមានក្នុងសម័យឥឡូវនេះទេ ហើយក្នុងនគរខ្មែរទាំងមូល ក៏មានជនានុជននិយមប្រើគ្រប់ៗស្រុកដែរ តែមានសេចក្ដីអធិប្បាយខុសៗ គ្នា ។ ចំពោះអ្នកស្រុកសិរីសោភ័ណវិញ គេយកសំអាងលើរឿងដូចខាងក្រោម ទង់នាគ – ទង់រលក

កាលណោះ ព្រះពុទ្ធបរមគ្រូនៃយើងទ្រង់ចូលបរិនិព្វានទៅហើយ ។ ពួកពុទ្ធបរិស័ទដែលប្រតិបត្តិតាមពុទ្ធវចនៈ ក្នុងកាលជាខាងក្រោយ មានកតញ្ញូកតវេទិតាចំពោះព្រះអង្គ ប្រាថ្នាលើកតម្កើងព្រះពុទ្ធសាសនា ក៏នាំគ្នាគិតកសាងកុឡាមណីចេតិយនៅទីកន្លែងមួយដ៏សមគួរ ដើម្បីបញ្ចុះព្រះសារីរិកធាតុរបស់ព្រះអង្គ ក៏តាំងចាត់ការកសាងមួយរំពេច, អ្នកខ្លះយកនេះ អ្នកខ្លះយកនោះ ទៅតាមកិច្ចដែលត្រូវធ្វើ ។

ក្សិណនោះឯង ស្រាប់តែពួកមារាធិរាជ នាំគ្នាមកផ្ចាញ់ផ្ចាល ជាឧបសគ្គមិនឲ្យចាត់ការកសាងបាន គឺធ្វើឲ្យអ្នកខ្លះចុកពោះ អ្នកខ្លះឈឺក្បាល អ្នកខ្លះគ្រុនញាក់ ហើមមុខមាត់ ដេកថ្ងូរ ទ្រហោយំ ស្រែកព្ធលាន់រំពងទ្រហឹងអឺងកង ។ ទើបមានបុរសម្នាក់ជាប្រមុខការ រត់ទៅពិតថេរដីកាដល់ព្រះឧបគតត្ថេរថា "ពួកអ្នកធ្វើការកសាងទាំងអម្បាលនោះ ឥឡូវនេះ ស្រាប់តែឈឺយំរងួយទាំងអស់គ្នា ឥតមានអ្នកណាធ្វើការកើតទេ" ។ ព្រះឧបគត ដែលជាអ្នកមានឥទ្ធិរិទ្ធិបាដិហារ្យ យល់ការច្បាស់ថា មិនមានអ្នកណាទេ ប្រាកដជាក្រុងមារធ្វើការផ្ចាញ់ផ្ចាលទៀតហើយ ។ លោកក៏និមន្តទៅសូត្រមន្តបាចទឹក ដាក់អំបោះឲ្យអ្នករងគ្រោះទាំងនោះ ។ រោគាព្យាធិ ក៏វិនាសខ្ចាត់ខ្ចាយអស់ទៅ ។ ក្រុងមារ ទាល់គំនិត ធ្វើអ្វីមិនកើត ក៏ក្លែងខ្លួនជាបុរសម្នាក់ ចូលទៅសុំបព្វជ្ជាក្នុងសម្នាក់ព្រះឧបគត ។ មុននឹងអនុញ្ញាតឲ្យបួស ឧបគតសួរយកការណ៍សព្វគ្រប់ ។ បុរសនោះទទួលថា "ខ្ញុំមកសុំបួស ដោយសទ្ធាជ្រះថ្លាពេញទី មិនមែនមកបួសបន្លំ ដើម្បីបង្ខូចសាសនាព្រះពុទ្ធទេ" ។ ទើបឧបគតអធិដ្ឋានដោយបញ្ចេញសំឡេងឲ្យលាន់ឮថា "ចីវរនេះ បើបុរសឯង បួសដោយការជ្រះថ្លាមែន សូមឲ្យស្ថិតនៅល្អជាប្រក្រតីចុះ, តែបើអ្នកឯងបួសដោយបន្លំ ដើម្បីផ្ចាញ់ផ្ចាលនូវពួកយើងជាអ្នកកាន់ព្រះពុទ្ធសាសនា សូមឲ្យចីវរនេះ ក្លាយទៅជាគំរង់ឆ្អែជាប់នៅនឹងកអ្នកឯង កុំឲ្យអ្នកឯណាជួយស្រាយបានឡើយ" ។ ព្រះឧបគតថាដូច្នោះហើយ ក៏លើកវត្ថពន្ធពាក់ជាដំបូង ។ ចីវរនោះ ក៏ក្លាយទៅជាគំរង់ឆ្អែក្នុងពេលនោះភ្លាម ។ បុរសគំរង់គឺក្រុងមារនោះ ក៏ស្ទុះរត់ទៅទាំងគំរង់ស្អុយជាប់នឹងខ្លួន សូមឲ្យគេជួយ ក៏មិនមានអ្នកណាជួយដោះបានសោះ ។ ទើបឧបគតប្រាប់ទៅពុទ្ធសាសនិកថា "ក្រុងមារ ក្លែងខ្លួនជាបុរសមកសុំផ្នួសនេះ គឺដើម្បីមកផ្ចាញ់ផ្ចាលពួកយើងអ្នកកាន់ពុទ្ធសាសនា មានរូបអាត្មាជាដើម តែមិនអីទេ ក្រុងមារនឹងវិនាសសាបសូន្យ ដោយឥទ្ធិរិទ្ធិរបស់យើងជាប្រាកដ" ។ ចំណែកក្នុងមារដែលជាប់សម្អុយ ស្ទុះរត់ទៅពឹងអ្នកឯណាជួយមិនបាន ព្រោះមន្តលោកឧបគតខ្លាំងពូកែណាស់ ទាល់គំនិត ក៏ចូលមកលន់តួសូមចុះចាញ់ ដោយទទួលកំហុសរបស់ខ្លួន ហើយអង្វរថា "សូមលោកម្ចាស់អភ័យទោស មេត្តាសង្គ្រោះស្រាយចំណងឲ្យទាន" ។ ព្រះឧបគតក៏ផ្ចាញ់ផ្ចាលក្រុងមារដោយប្រការផ្សេងៗ ព្រមទាំងចាប់ក្រុងមារយកទៅចងភ្ជាប់នៅនឹងកំពូលភ្នំគិជ្ឈកូដផង ។ ក្រុងមារខឹងណាស់ក៏ស្ទុះផ្ដាច់ចំណងទៅទាំងត្រដរ ។ ចំណងឧបគត ក៏យឺតចេញទៅចម្ងាយពីរព្យាម រួចរួញកន្ត្រាក់ក្រុងមារមកវិញ ឲ្យទង្គិចនឹងថ្មភ្នំស្ទើរស្លាប់អស់វារៈ ៣ដង ព្រោះចំណង

នោះឃើតដូចកៅស៊ូ ទាញទៅរួញមក ដោយមន្តរបស់ព្រះឧបគត ។ ក្រុងមារទាល់គំនិត ក៏ទ្រហោយំរៀបរាប់គ្រប់ប្រការថា "កាលព្រះពុទ្ធគង់នៅឡើយ មិនដែលអគ្គសាវកអង្គណា មកបៀតបៀនខ្លួនអាត្មាអញដូច្នេះម្ដងសោះ ទើបតែអង្គឧបគតនេះ ធ្វើបាបខ្លួនអញយ៉ាងទារុណជាទីបំផុត" ។ ព្រះឧបគតបានឮសំឡេងក្រុងមារ ទើបមានថេរដីកាផ្ទាញ់ផ្ទាល់ដោយប្រការផ្សេងៗ ហើយប្រាប់ទៅក្រុងមារថា "ចូរឯងរាងចាល កុំឲ្យធ្វើអំពើដ៏លាមកដូច្នេះទៀត តាំងពីថ្ងៃនេះតទៅ" ។ ក្រុងមារឆ្លើយថា "ខ្ញុំព្រះករុណារាងចាលហើយ សូមលោកមេត្តាស្រាយចំណងចេញទៅ" ។ ព្រះឧបគតប្រាប់បញ្ជាក់ទៅទៀតថា "ចាប់ដើមពីថ្ងៃនេះទៅ បើនៅទីកន្លែងណា គេធ្វើបុណ្យតាមលំអានសាសនាព្រះពុទ្ធ ចូរឯងកុំបៀតបៀនគេឲ្យសោះណា" ។ ក្រុងមារឆ្លើយថា "ខ្ញុំព្រះករុណាចាំបានហើយ សូមមេត្តាសង្គ្រោះខ្ញុំផង ដ្បិតខ្ញុំទ្រាំស្អុយនេះ មិនបានទេ ដាច់ខ្យល់ស្លាប់ឥឡូវហើយ" ។ ព្រះឧបគតប្រាប់ហើយប្រាប់ទៀតថា "កន្លែងណា ដែលគេធ្វើបុណ្យតាមលំអានសាសនាព្រះពុទ្ធនឹងមានដោតទង់រលក ឬទង់នាគជាគ្រឿងសម្គាល់, ចូរពួកឯងរាល់គ្នាជួយសោមនស្សត្រេកអរអនុមោទនា កុំបីអ្នកឯណាមកបៀតបៀនឡើយ" ។

ព្រោះហេតុដូច្នោះ បានជាទីកន្លែងណាដែលគេធ្វើបុណ្យ គេតែងដោតទង់រលក ឬទង់នាគ ជាសញ្ញាប្រកាសឃោសនាប្រាប់ឲ្យអ្នកផងដឹងច្បាស់ថា "កន្លែងនោះ គេធ្វើបុណ្យទេតើ !" ។ ម្យ៉ាងទៀត ទង់នេះមានសញ្ញាទ្រង់ទ្រាយខុសៗ គ្នា តាមការរចនារបស់ជាង ។ ទង់ក្រពើ

កាលណោះ ម្ចាស់ដែនដីនេះ ឈ្មោះ ក្រុងពាលី ព្រះពុទ្ធជាម្ចាស់ ព្រះអង្គបានត្រាស់ដឹងក្នុងលោក កាលបើទ្រង់ឃើញក្រុងពាលីជាមនុស្សវង្វេង តែមាននិស្ស័យគួរព្រះអង្គប្រោសបាន ទើបប្រើឧបាយសុំបិណ្ឌបាតដីដោយពាក្យថា "ក្រុងពាលី ! តថាគតសុំដីនេះចំនួនប៉ុនចីពរផងបានទេ ?" ។ ក្រុងពាលីឆ្លើយថា "សមណៈយកដីធ្វើអ្វីតូចម្ល៉េះ!" ។ ទើបព្រះអង្គមានពុទ្ធដីកាថា "តថាគតចង់បានធំដែរ តែមិនហ៊ានសុំ, បើដូច្នោះតថាគតសុំចំនួន ៣ ជំហានចុះ !" ។ ក្រុងពាលីឆ្លើយថា "ព្រះអង្គយកចុះ" ។ ទើបព្រះពុទ្ធជាម្ចាស់សម្ដែងបាដិហារ្យ ឈានយកផែនដីទាំងមូល បានតែត្រឹមចំនួន ២ ជំហានកន្លះ អស់ផែនដី ។ ក្រុងពាលីទាល់ប្រាជ្ញា គិតថា "ផែនដីរបស់អញនេះ ឃើញធំណាស់ដែរ ចុះហេតុអ្វីបានជាតូចម្ល៉េះ ! សូម្បីតែលើកថ្វាយព្រះពុទ្ធចំនួន ៣ ជំហាន ក៏មិនគ្រប់ផង" ។ ក្រុងពាលីសញ្ជឹងគិតតែម្នាក់ឯងដូច្នេះ ហើយក៏គៀសខ្លួនដើរចេញអំពីផែនដីដែលត្រូវបានទៅព្រះពុទ្ធ រួចខ្លួនឯងក៏អស់ដីនៅតាំងពីត្រឹមហ្នឹងមក ទើបកាឡាខ្លួនជាក្រពើ ទៅនៅក្រៅកណ្ដាប់ចក្រវាល ។ ព្រះសមណគោតម ទ្រង់ជ្រាបច្បាស់ដូច្នោះ ក៏តាមទៅទៀត ។ ក្រពើយល់បានថា "នេះ មិនគឺអ្នកណាទេ ប្រាកដជាសមណៈនោះហើយ" ទើបសួរទៅថា "ចុះសមណៈមកទីនេះធ្វើអ្វី ? សុំយកដីយើងទាំងអស់ទៅហើយ ។ យើងមកសម្ងំនៅក្នុងទឹកឯណេះ, តើសមណៈចង់បានទឹកទៀតឬ បានជាមកតាមយើងដូច្នេះ ?" ។ ព្រះសមណគោតមឆ្លើយ " តថាគតមកនេះ ដោយបំណាងពឹងក្រពើឯងតើ !" ។

- - ពឹងការអ្វី ?
- - ពឹងឲ្យចម្លង !
- - ពឹងពុំបានទេ, បើជួលឲ្យអាហារស៊ី ទើបបាន ។
- - មិនអីទេ ! ចាំតថាគតឲ្យអាហារឆ្ងាញ់ដល់អ្នកឯងស៊ី ។

ក្រពើ និងព្រះសម្មាសម្ពុទ្ធក៏ព្រមព្រៀងគ្នា ហើយក្រពើប្រាប់ទៅព្រះអង្គថា "ជិះក្បាលខ្ញុំមិនបានទេ" ។ ព្រះសម្មាសម្ពុទ្ធឆ្លើយថា "ធម្មតាម្ចាស់ឈ្នួល ស្រេចតែនឹងចិត្ត ចង់ជិះត្រង់ណាក៏បានដែរ, ឯងស៊ីឈ្នួលគេមិនត្រូវប្រកែកទេ" ។ ក្រពើទាល់គំនិត ដោយការព្រមព្រៀងគ្នាជាស្រេចទៅហើយ រកនិយាយមិនរួច ម៉្លោះហើយ ត្រូវស៊ូទ្រាំទៅតាមកម្ម ។ ព្រះពុទ្ធអង្គក៏ឡើងជិះលើក្បាលក្រពើ ធ្ងន់មហាធ្ងន់ ព្រោះកម្លាំងឥទ្ធិរិទ្ធិ ។ ក្រពើជ្រមុជចុះទៅក្នុងទឹកជ្រៅ ព្រោះធន់នឹងទម្ងន់មិនបាន ក៏ទទួលសុំចុះចាញ់ព្រះអង្គក្នុងពេលនោះ ។ បំណងរបស់ក្រពើ ចង់ឲ្យព្រះពុទ្ធអង្គជិះខ្នង តែព្រះអង្គមិនព្រម ដោយចង់ឈ្នះក្រពើ ទើបជិះក្បាល ។ ព្រះសម្ពុទ្ធជ្រាបច្បាស់ថា "និស្ស័យរបស់ក្រុងពាលី ចុះក្នុងសំណាញ់ញាណរបស់ព្រះអង្គហើយ ទើបព្រះអង្គសម្ដែងធម៌ប្រោស អំពីអរិយសច្ចធម៌ ៤ យ៉ាង ។ ក្រពើ មានសេចក្ដីជ្រះថ្លាចំពោះព្រះអង្គ ក៏ដកចង្កូមទាំង ៤ ថ្វាយព្រះអង្គក្នុងពេលនោះទៅ ។

ព្រោះហេតុដូច្នោះហើយ បានជានៅពេលធ្វើបុណ្យបូជាខ្មោច ត្រូវមានទង់ក្រពើ ព្រោះត្រូវការអាស្រ័យនឹងផែនដី ។ ឯកិច្ចការសព្វសារពើ ដូចជាសងផ្ទះ សាលាជាដើម លើផែនដី ក៏ត្រូវឲ្យសែនក្រុងពាលីជាម្ចាស់ដីសិនដែរ ទើបបានសុខសប្បាយ ។

រឿងនេះ មាននៅក្នុងសាស្ត្រាមាណព ។